# រឿងអាលី-បាបានិងចោរ៤០នាក់ ត្រូវបង់ជីវិត ដោយសារទាសីម្នាក់

(ភាគទី៤៤)

យប់តមកទៀត, នាងសេហេរាសាដក៏និយាយទៅកាន់នាងសារិយាថា នៅក្នុងរាជធានីមួយនៃរាជធានីនៃប្រទេសពែរ្ស៍ (Perse) ជាប់ព្រំប្រទល់ដែននៃរដ្ឋរបស់ព្រះមហាក្សត្រិយ៍យើងនេះ, មានបងប្អូនប្រុសពីរនាក់ ម្នាក់ឈ្មោះកាស៊្សីម (Cassim), ម្នាក់ទៀតឈ្មោះអាលី-បាបា (Ali-Baba) ។ បិតានៃកុមារទាំងពីរនេះបានសល់ទ្រព្យសម្បត្តិបន្តិចបន្តួច, គាត់ក៏បានចែកទ្រព្យសម្បត្តិកេរអាករទាំងនោះឱ្យកូនស្មើភាគគ្នា ។ ប៉ុន្តែវាសនាមនុស្សមកឱ្យខុសគ្នា ។

កាស៊្សីមបានរៀបការជាមួយស្ត្រីម្នាក់, ដែលកំឡុងពេលក្រោយមង្គលកិច្ចនេះបន្តិចមក, ក៏បានទទួលមរតកនូវហាងមួយមានរបស់ពេញ, ឃ្លាំងមួយទៀតផ្ទុកពេញទៅដោយទំនិញល្អៗ ព្រមទាំងដីមួយកន្លែង ។ ដូច្នេះ, មិនយូរប៉ុន្មាន, កាស៊្សីមក៏បានទៅជាពាណិជម្នាក់មានផុតគេក្នុងរាជធានី ។

ផ្ទុយទៅវិញ, អាលី-បាបា ប្អូនដែលបានរៀបការជាមួយស្ត្រីម្នាក់ក្រជាងខ្លួនទៅទៀត, រស់នៅក្រោមដំបូលយ៉ាងកម្សត់ទុរគត ។

វាគ្មានរបរអ្វីដើម្បីចិញ្ចឹមពោះ និងស្បៀកពាក់ឱ្យប្រពន្ធកូននិងខ្លួនវា ក្រៅអំពីចូលព្រៃជិតខាងរកស៊ីកាប់អុស, កាប់បានហើយក៏ផ្ទុកលើខ្នងលា ៣ យកមកលក់ឯទីក្រុង ។

សម័យថ្ងៃមួយ, អាលី-បាបាកំពុងនៅក្នុងព្រៃ ហើយទើបតែនឹងកាប់អុសបានគ្រប់បន្ទុកលាវាទាំងបី, ស្រាប់តែវាក្រឡេកទៅឃើញធូលីមួយដុំធំហុយទ្រលោមឡើងទៅលើអាកាស ហើយចេះតែរំកិលចំមករកវា។ វាខំពិនិត្យយ៉ាងម៉ត់ចត់ស្រាប់តែឃើញមនុស្សជិះសេះមួយហ្វូងធំ កំពុងបំផាយសេះចូលមក ។

ពិតមែនតែក្នុងនគរគេពុំដែលបានដំណាលពីរឿងចោរសោះ, ក៏អាលី-បាបាយល់បានភ្លាមថា អ្នកជិះសេះទាំងនេះប្រហែលជាពួកចោរហើយ ។ ដោយឥតគិតពីលារបស់ខ្លួន វានឹងទៅជាយ៉ាណានោះទេ អាលី-បាបាគិតតែពីរត់គេចខ្លួនពួនអាត្មាឱ្យផុត គឺវាបានស្រវាឡើងដើមឈើមួយធំ, ដែលមានមែកដុះបែកចាក់ស្រែះប្រទាក់ប្រទាញគ្នាជារង់មូល បន្តបន្ទាប់គ្នាជាលំដាប់ទៅលើ ប៉ុន្តែមានចន្លោះជិតៗគ្នា ។ វាក៏ឡើងទៅពួនក្នុងទីនោះ ដោយប្រាកដក្នុងចិត្តថា វាអាចមើលគេឃើញ តែគេឥតមើលឃើញវិញឡើយ ។ ដើមឈើនោះដុះចេញពីជើងភ្នំដែលពុំសូវមានមនុស្សម្នាណាទៅដល់សោះ ។ ភ្នំនោះខ្ពស់ក្រៃណាខ្ពស់ជាងដើមឈើទៅទៀត, ហើយចោតមើលទៅទំនងគ្មានកន្លែងត្រង់ណា ដែលអាចឱ្យមនុស្សឡើងបានទៅដល់លើឡើយ ។



អ្នកជិះសេះទាំងនោះមានមាឌធំៗ ហើយក្លាហានមានអាវុធយុទ្ធភ័ណ្ឌកាន់គ្រប់ដៃ, ចូលមកដល់ទីជិតភ្នំនោះ រួចក៏ចុះពីលើខ្នងសេះគ្រប់គ្នា ។ អាលី-បាបា បានរាប់ទៅឃើញចំនួន៤០ ។ ដោយសង្កេតមើលទឹកមុខនិងគ្រឿងសម្ភារៈទូទៅ, អាលី-បាបាអស់សង្ស័យទៀតហើយថា គឺពិតជាពួកចោរ ។ វាមិនច្រឡំទេ ពួកនោះឥតប្រកបរបរលួចប្លន់របស់ខ្លួននៅទីជិតៗនេះទេ ពួកវាបបួលគ្នាទៅរកស៊ីនៅទីកន្លែងឆ្ងាយៗ ។ ឯទីនេះគឺជាកន្លែងដែលវាសម្រាប់មកជួបគ្នាតែប៉ុណ្ណោះ។

អ្នកជិះសេះម្នាក់ៗ បានស្រាយបង្ហៀរសេះរបស់ខ្លួនចេញ យកសេះចង រួចយកបាវស្រូវសាឡី ដែលវាបានព្រនាក់លើខ្នងសេះខាងក្រោយ មកចងនឹងកសេះ ទើបម្នាក់ៗដោះយកហិបយួររៀងៗខ្លួន ។ បណ្ដាហិបទាំងនោះ អាលី-បាបាមើលទៅឃើញសុទ្ធតែធ្ងន់ៗ ដែលវាអាចយល់បានថា នៅក្នុងហិបនោះគេច្រកសុទ្ធតែមាសនិងប្រាក់សម្រាប់ចាយ ។

ជនម្នាក់មានឫកសម្បើមជាងគេ ដែលអាលី-បាបាសម្គាល់ថាជាមេលើគេ ហើយយួរហិបដូចជាគេឯទៀតដែរ, បានដើរចូលទៅជិតថ្មភ្នំ ។ ថ្មនោះស្ថិតនៅជិតបង្កើយនឹងដើមឈើដែលវាពួន ។ តមកជនមេក្រុមនោះក៏ពោលពាក្យដូចតទៅថា : “សេសាម, ចូរឯងបើក” ។ អាលី-បាបាក៏បានស្ដាប់ឮទាំងអស់ ។ លុះមេចោរថាដូច្នោះរួច ទ្វារក៏





របើក ។ រួចវាឱ្យកូនចោរទាំងឡាយចូលទៅមុន ទើបវាចូលតាមក្រោយ ។ ឯទ្វារក៏បិទទៅវិញ ។ ពួកចោរទាំងឡាយបានស្ថិតនៅក្នុងរូងថ្មនេះអស់ពេលជាយូរ ។ អាលី-បាបា ដោយខ្លាចក្រែងចោរណាម្នាក់ ឬក៏ចោរទាំងអស់បើកទ្វារចេញមកឃើញ, បើសិនជាលបចុះពីកន្លែងនោះដើម្បីរត់គេចខ្លួន, ក៏ទ្រាំអង្គុយនៅទីនោះដោយសេចក្តីអន្ទះអន្ទែងចិត្ត ។ ប៉ុណ្ណឹងក៏ដោយ, អាលី-បាបា នៅតែចង់ចុះពីលើដើមឈើ, ចង់ល្បងលួចយកសេះរបស់អាចោរឱ្យបានពីរ គឺជិះមួយដឹកមួយ ហើយជិះប្រដេញលារបស់ខ្លួនបីឱ្យវាទៅជាមួយ តម្រង់ទៅទីក្រុងផង ។ ប៉ុន្តែការមិនទុកចិត្តនឹងព្រឹត្តិការណ៍បានឃាត់អាលី-បាបាឱ្យសម្ងំពួននៅទីនេះសិនល្អជាង ។

ទីបំផុតទ្វារក៏របើកឯង ចោរទាំង៤០ ចេញមក ម្តងនេះមេចោរដែលចូលទៅក្រោយគេ ទៅជាចេញមកមុនគេ ។ លុះចោរទាំងឡាយចេញផុតពីរូងថ្មហើយ, អាលី-បាបាក៏ឮមេចោរពោលឱ្យបិទទ្វារទៅវិញដោយពាក្យថា : “សេសាម, បិទទ្វារវិញ” ។ ចោរម្នាក់ៗក៏ដើរតម្រង់ទៅកាន់សេះរៀងៗខ្លួន, ចងបង្ហៀរ, ចងហិបរួចក៏ឡើងជិះ ។ កាលបើមេចោរសង្កេតឃើញថា ពួកក្រុមរបស់ខ្លួនរៀបចំខ្លួនជាស្រេចហើយ វាក៏ញាក់សេះទៅមុខគេបង្អស់ រួចក៏បរចេញទៅទាំងអស់គ្នា តាមផ្លូវដែលវាបានមក ។

ដំណាលពីអាលី-បាបាម្តងវិញ, វាពុំទាន់ចុះពីលើដើមឈើភ្លាម

ទេ វានឹកក្នុងចិត្តថា “ពួកចោរទាំងនេះពុំខានមានភ្លេចអ្វី ហើយត្រឡប់មកវិញទេ បើសិនជាអញចុះភ្លាម អញនឹងត្រូវពួកវាចាប់បាន បើសិនជាការណ៍នេះមានដូច្នេះមែន” ។ វាសម្លឹងតាមមើលពួកចោរលុះត្រាតែផុតកន្ទុយភ្នែក អស់ពេលដ៏យូរបន្តិចមក ទើបវាចុះដោយសេចក្ដីកក់ក្ដៅក្នុងចិត្ត ។ អាលី-បាបាបានចាំទាំងអស់នូវសម្ដីដែលមេចោរពោលបើកទ្វារ-បិទទ្វារ ។ ដូច្នេះវាចង់ល្បងមើល តើពាក្យនេះអាចឱ្យផលដូចជាមេចោរវាពោលទេ។ វាក៏ដើរតម្រង់ទៅមាត់ទ្វារថ្មនោះ, ឈរចំពីមុខហើយនិយាយថា : “សេសាម ចូរឯងបើក” ។ មួយរំពេចទ្វារក៏បើកចំហយ៉ាងធំ អាលីបាបា ក៏ឈរមើលទៅក្នុងទីដ៏ងងឹតនោះ, ប៉ុន្តែ វាមានចិត្តឆ្ងល់ ដោយឃើញកន្លែងមួយភ្លឺច្បាស់, ធំទូលាយ, ជីកដោយដៃមនុស្សមានរាងជាបរិមណ្ឌលយ៉ាងខ្ពស់, មានពន្លឺចាំងចូលតាមប្រហោងមួយដែលគេចោះពីខាងលើ ។ វាឃើញគ្រឿងសម្រាប់បរិភោគ, បង្វេចសម្ពាយដាក់វត្ថុល្អៗគរត្រួតបន្ទុបលើគ្នា, កំណាត់សំពត់ធ្វើអំពីសូត្រ, កំណាត់ចរបាប់, កម្រាលព្រំដ៏ថ្លៃៗ ហើយជាពិសេសគឺមាសហើយនិងប្រាក់ច្រកក្នុងបាវឬថង់ធំៗ ធ្វើអំពីស្បែក គរជាគំនរៗលើគ្នា ។ ឃើញដូច្នោះ, អាលី-បាបាយល់ថា ពួកចោរមិនមែនទើបតែនឹងប្រកបមុខរបរវាក្នុងពេលពីរ-បីឆ្នាំនេះទេ គឺពិតជាច្រើនសតវត្សរ៍មកហើយ ។ រូងថ្មនេះជាកន្លែងសម្រាប់ពួកចោរគ្នាវានៅតៗគ្នាមក ។

អាលី-បាបា ឈប់គិតពីមធ្យោបាយដែលខ្លួនត្រូវប្រកាន់យក



សិន វាបានចូលទៅក្នុងរូងថ្ម ។ លុះចូលផុតភ្លាម, ទ្វារក៏បិទទៅវិញ, ប៉ុន្តែការនេះមិនធ្វើឱ្យវាបារម្ភទេ ។ វាស្គាល់នូវការអាថិកំបាំងអាចធ្វើឱ្យទ្វារនេះរបើកវិញ ។ អាលី-បាបាមិនសូវរវល់នឹងគ្រឿងប្រាក់ទេ, វាគិតតែអំពីមាស ហើយជាពិសេសមាសដែលនៅក្នុងបាវ ។ វាបានលើកជញ្ជូនយកបាវមាសជាច្រើនដង តាមកម្លាំងវាអាចយកបាន, ដើម្បីឱ្យគ្រប់បន្ទុកលាវាទាំងបី ។ វាបានប្រមូលលាវា ដែលនៅរាត់រាយរួចដឹកយកមកជិតរូងថ្មនោះលើកបាវផ្ទុក ។ ប៉ុន្តែដើម្បីនឹងលាក់វត្ថុនោះកុំឱ្យគេឃើញ វាបានយកអុសដាក់ពីលើទៀត។ លុះរៀបចំស្រេចបាច់ហើយ, វាក៏ចេញមកខាងក្រៅ ។ រួចក្រោយពីពោលថា : “សេសាម បិទទ្វារទៅវិញ” , ទ្វារក៏បិទភ្លាម, ព្រោះទ្វារនេះបិទឯង កាលដែលវាចូលហើយ នៅចំហនៅពេលដែលគាត់ចេញ ។

ធ្វើដូច្នេះរួចស្រេចហើយ, អាលី-បាបា ក៏បរលាទៅកាន់ផ្លូវតម្រង់ទៅទីក្រុងវិញ ។ លុះទៅដល់ផ្ទះវា ក៏បញ្ចូលលានោះទៅក្នុងទីធ្លាតូចមួយ បិទទ្វារយ៉ាងជិត រួចដាក់អុសបន្តិចបន្តួចលើខ្នងលាមកដីរួចយួរបាវទាំងឡាយមកដាក់តម្រៀបនៅមុខប្រពន្ធវាដែលអង្គុយនៅលើកៅអីវែង ។

ប្រពន្ធវាក៏យកដៃស្ទាបបាវមើល លុះសង្កេតឃើញបាវនោះមានសុទ្ធតែប្រាក់, គាត់ក៏មានសេចក្ដីសង្ស័យថា ប្ដីគាត់បានលួចគេយកមក ។ លុះប្ដីគាត់ជញ្ជូនអីវ៉ាន់មកទុកអស់, គាត់អត់ទ្រាំនឹងសួរប្ដី

គាត់ពុំបាន ទើបសួរថា : "បងអាលី-បាបាអ្នកនឹងទៅជាមនុស្សអភ័ព្វដោយសារ....." អាលី-បាបាក៏ឆ្លើយកាត់ភ្លាមថា : "ស៊ូហ៎ ! ...នៅឱ្យស្ងៀមឯងកុំអាលភ្ញាក់ផ្អើលអ្វីឱ្យសោះ ។ ខ្ញុំមិនមែនចោរទេ ប៉ុន្តែបើសិនជាខ្ញុំចោរ ក៏ខ្ញុំលួចតែពីពួកចោរដែរ ។ ឯងនឹងឈប់យល់ដូច្នេះ, កាលបើខ្ញុំនិយាយប្រាប់ឯងអំពីសំណាងល្អរបស់ខ្ញុំ" ។

- អាលី-បាបា ក៏រលាក់របស់នោះចេញពីបាវមក ឃើញសុទ្ធតែមាសមួយគំនរធំ, ធ្វើឱ្យប្រពន្ធវាភ្លឹកបាត់ស្មារតី ។ កាលបើវាធ្វើការនេះរួចហើយ វាក៏និយាយរឿងផ្សងព្រេងរបស់វាប្រាប់ប្រពន្ធ ចាប់តាំងពីដំបូងរហូតដល់ចប់ ។ លុះនិយាយចប់, វាក៏ហាមប្រពន្ធកុំឱ្យនិយាយការសម្ងាត់នេះប្រាប់នរណាឱ្យសោះ ។

ប្រពន្ធវា កាលបើដឹងខ្លួនស្រួលបួលឡើងវិញ ក៏សប្បាយចិត្តជាមួយនឹងប្ដីចំពោះសុភមង្គលដែលកើតមានឡើងដល់ជនទាំងពីរ ។ នាងចង់រាប់លុយមាសនោះមួយដុំម្ដងៗ ប៉ុន្តែអាលី-បាបាបាននិយាយឡើងថា : "ឯងអើយ, ឯងនេះមិនមែនជាមនុស្សប្រកបដោយគតិបណ្ឌិតទេ តើឯងគិតធ្វើម៉េចហ្នឹង? ចុះពេលណាទៅបានឯងរាប់ចំនួនរបស់នេះហើយ? យើងគ្មានត្រូវធ្វើពេលឱ្យខាតទេ" ។ ខ្ញុំនឹងទៅជីករណ្ដៅមួយ ដើម្បីយកលុយមាសនេះទៅកប់ ប្រពន្ធក៏ឆ្លើយថា :

- "ល្អហើយគិតដូច្នេះ, ប៉ុន្តែយ៉ាងហោចណាស់ក៏យើងត្រូវដឹងចំនួនរបស់ប្រហែលៗដែរ ខ្ញុំនឹងទៅរករង្វាស់រង្វាល់នៅផ្ទះគេជិតខាង ហើយខ្ញុំនឹងវាល់ចំនួនរបស់នេះនៅពេលឯងជីករណ្ដៅ" ។



- "នែឯងអើយ, (អាលី-បាបា ឆ្លើយ), ការដែលឯងគិតធ្វើនេះគ្មានបានប្រយោជន៍អ្វីទាំងអស់ ។ ត្រូវឯងឈប់ធ្វើទៅ, បើឯងព្រមជឿតាមយើង ។ ប៉ុន្តែបើឯងចង់ធ្វើក៏ធ្វើទៅ, សូមប្រយ័ត្នតែកុំឱ្យការណ៍នេះបែកធ្លាយ" ។

ដើម្បីនឹងបំពេញសេចក្ដីស្រេកឃ្លានរបស់ខ្លួន ប្រពន្ធអាលី-បាបា ក៏ចេញពីផ្ទះទៅៗ កាន់ផ្ទះបុរសកាស៊ីមជាបងថ្លៃ ដែលនៅមិនឆ្ងាយពីគ្នាប៉ុន្មាន ។ ពេលនោះ កាស៊ីមមិនបាននៅផ្ទះទេ នៅតែប្រពន្ធគាត់ ។ ដូច្នេះ, ប្រពន្ធអាលី-បាបា ក៏សុំខ្ចីរង្វាល់ពីប្រពន្ធគាត់មួយភ្លែត ។ បងថ្លៃស្រីក៏សួរមកវិញថា តើគាត់ចង់បានអាធំឬអាតូច, ប្រពន្ធអាលី-បាបា ក៏សុំខ្ចីអាតូច ។

បងថ្លៃក៏ចូលទៅរករង្វាល់, គាត់ក៏បានឃើញភ្លាម, ប៉ុន្តែមិនទាន់យកចេញមកភ្លាមទេ ដោយគាត់ធ្លាប់ស្គាល់ទុគ៌តភាពអាលី-បាបា, គាត់ចង់ដឹងណាស់ថា តើប្រពន្ធ អាលី-បាបា ត្រូវការវាល់គ្រាប់អ្វី ។ មួយសន្ទុះមក, ទើបគាត់យករង្វាល់នោះទៅប្រឡាក់នឹងម្រែងភ្លើងពីខាងក្រោម ។ រួចគាត់ក៏ចេញមកវិញ, យករបស់នោះមកហុចឱ្យប្អូនថ្លៃដោយនិយាយសុំទោសថា បានជាយូរមកពីរកក្រឃើញ ។

ប្រពន្ធអាលី-បាបា ក៏ត្រឡប់មកផ្ទះវិញ, គាត់ដាក់រង្វាល់ទៅលើគំនរមាស, រួចវាល់ចាក់ទៅលើកោអីវែងឆ្ងាយពីកន្លែងនោះបន្តិច ។ គាត់ធ្វើដូច្នេះលុះត្រាតែហើយៗរីករាយសប្បាយចិត្តដោយវាល់ឃើញ

មានចំនួនជាច្រើន ។ នាងក៏យកដំណឹងនេះទៅនិយាយប្រាប់ប្ដីដែលទើបនឹងជីករណ្ដៅរួច ។

នៅពេលដែល អាលី-បាបា រៀបចំកប់មាស ប្រពន្ធវា ដើម្បីរក្សានូវសេចក្ដីទៀងទាត់ នឹងការរហ័សរហួន, ក៏យករង្វាល់ទៅជូនបងថ្លៃវិញ ។ ប៉ុន្តែដោយពុំបានប្រយ័ត្ន, ដុំមាសមួយបាននៅជាប់ពីក្រោមគូថរង្វាល់ ។

“អ្នក, អ្នកឃើញទេ ខ្ញុំមិនយករង្វាល់អ្នកទៅទុកយូរទេ, ខ្ញុំអរគុណអ្នកហើយ, ខ្ញុំសូមជូនរង្វាល់ផង, ប្រពន្ធ អាលី-បាបា ចរចា” ។

ប្រពន្ធ អាលី-បាបា បែរខ្នងត្រឡប់ទៅវិញស្ទើរតែពុំទាន់ផុតផង, ប្រពន្ធកាស៊ីមក៏សម្លឹងមើលរង្វាល់ពីខាងក្រោមភ្លាម, រួចក៏មានសេចក្ដីងឿងឆ្ងល់ឥតឧបមា ដោយបានឃើញដុំមាសមួយដុំជាប់នៅនោះ ។

សេចក្ដីឈ្នានីស ក៏រត់មកគ្របដណ្ដប់លើប្រអប់បេះដូងនាងមួយរំពេច ។ នាងនឹកថា : “យី ! អាលី-បាបា មានមាសដល់ទៅវាល់ តើជនអភ័ព្វនេះបានមាសមកពីណា?” ។

ដូចយើងបានជម្រាបអ្នកអានមកហើយថា កាស៊ីមប្ដីនាងមិនបាននៅផ្ទះទេក្នុងពេលនោះ គាត់នៅឯហាងធ្វើការ លុះដល់ល្ងាចទើបគាត់ត្រឡប់មកវិញ ។ ដោយមានចិត្តអន្ទះអន្ទែងចង់និយាយរឿងនេះប្រាប់ប្ដីគាត់ខ្លាំងពេក ពេលវេលាដែលគាត់បានទន្ទឹងចាំប្ដីគាត់ហាក់ដូចជាយូរអស់មួយសតវត្សរ៍មកហើយ ។



កាលបើ កាស៊ីម ត្រឡប់មកដល់ផ្ទះភ្លាម ប្រពន្ធគាត់ក៏និយាយមកកាន់គាត់ភ្លាមថា : “ឯងនឹកស្មានថាខ្លួនឯងមានហើយ, តាមពិតឯងច្រឡំសោះ អាលី-បាបាមានជាងឯងហៅពុំឮ វាមិនមែនរាប់មាសដូចយើងទេ គឺវាវាល់តែម្ដង” ។

កាស៊ីម ក៏ឱ្យប្រពន្ធនិយាយរឿងនោះប្រាប់ ប្រពន្ធក៏និយាយបំភ្លឺរឿងនោះប្រាប់, អំពីហេតុដែលបណ្ដាលឱ្យនាងជ្រាបនូវការណ៍នោះ ។ រួចនាងក៏ហុចដុំមាស ដែលជាប់នៅនឹងបាតរង្វាល់ទៅឱ្យប្ដីមើល មាសនោះជារូបិយ៍ពីជាន់បុរាណយូរណាស់មកហើយ ព្រោះរូបព្រះអង្គម្ចាស់ ដែលគេបោះជាប់នៅលើលុយនោះ, ប្ដីនាងក៏ពុំស្គាល់ដែរ ។

មិនឯជួយត្រេកអរដល់សុភមង្គលរបស់ប្អូន ដែលអាចធ្វើឱ្យប្អូនងើបមុខរួច ពីសេចក្ដីលំបាកតោកយាក, កាស៊ីមបែរត្រឡប់ទៅជាមានចិត្តច្រណែនរកអ្វីប្រៀបគ្មាន គាត់ដេកគិតពីរឿងនេះអស់មួយយប់ គ្មាននិទ្រាលក់បន្តិចសោះ ។ លុះស្អែកឡើង, កាស៊ីមក៏ទៅកាន់ផ្ទះប្អូនតាំងពីពេលថ្ងៃពុំទាន់រះម៉្លេះ គាត់លែងទុកប្អូនគាត់ជាប្អូនបង្កើតចេញពីឧទរជាមួយគ្នាទៀតហើយ ។ គាត់បានបំភ្លេចឈ្មោះប្អូនគាត់ចោល តាំងពីគាត់បានរៀបការជាមួយស្រីមេម៉ាយដ៏ស្ដុកស្ដម្ភនេះមក ។ ដូច្នេះ, គាត់ក៏ដើរទៅជិត អាលី-បាបា ហើយពោលថា : "អាលី-បាបា អ្នកប្រសប់ចាត់ចែងកិច្ចការអ្នកណាស់, អ្នកដាក់ខ្លួនធ្វើជាអ្នកក្រ, អ្នកកម្សត់, អ្នករហេមរហាម, ប៉ុន្តែអ្នកមានមាសដល់ទៅវាល់ !

-លោកបង, (អាលី-បាបាដោះសា) ខ្ញុំពុំទាន់ដឹងលោកបងចង់និយាយនឹងខ្ញុំថាម៉េចទេ, សូមពន្យល់ខ្ញុំមកមើល ។

-កុំធ្វើល្ងង់ពុំដឹងអ្វីនោះ, (កាស៊ីមបន្តសំនួរ), ដោយហុចដុំមាសដែលប្រពន្ធគាត់ឱ្យៗទៅអាលីបាបា, ហើយសួរបន្ថែមទៀតថា : "តើឯងមានលុយមាសដូច្នេះប៉ុន្មានទៀត, ប្រពន្ធខ្ញុំគេបានឃើញរបស់នេះជាប់នៅនឹងបាតរង្វាល់ ដែលប្រពន្ធឯងទៅខ្ចីយកមកពីម្សិលមិញ?" ។

ឮដូច្នេះ, អាលី-បាបា ក៏ដឹងមួយរំពេចថា កាស៊ីមនឹងប្រពន្ធបានដឹងនូវការសម្ងាត់របស់ខ្លួនស្រេច, ដោយសារការរបើងរឹងរូសនៃប្រពន្ធវា មិនព្រមស្តាប់វា ។ ប៉ុន្តែកំហុសនេះធ្វើរួចទៅហើយ គេពុំអាចជួសជុលឡើងវិញបានទេ ។

ឥតមានបង្អង់ពេលឱ្យបងវាកើតសេចក្តីឆ្ងល់និងទោមនស្សបន្តិចឡើយ, អាលី-បាបាក៏និយាយរឿងហេតុ ដែលបណ្តាលឱ្យវារកឃើញកន្លែងជម្រកនៃពួកចោរប្រាប់បងវាភ្លាម ហើយគាត់ក៏ព្រមចែកឃ្លាំងនោះទៅបងគាត់, សូមឱ្យបងគាត់លាក់ការណ៍នេះឱ្យជិត ។

"ខ្ញុំយល់ព្រមតាម, កាស៊ីមឆ្លើយដោយទឹកមុខរីករាយ ប៉ុន្តែខ្ញុំចង់ដឹងឱ្យច្បាស់ជាងនេះទៅទៀតថា តើឃ្លាំងនោះនៅត្រង់កន្លែងណា, មានសញ្ញាមានគ្រឿងសម្គាល់ដូចម្តេច, ហើយតើខ្ញុំនឹងអាចទៅក្នុងរូងនោះម្តេចបាន, បើសិនជាខ្ញុំមានចិត្តចង់ចូល ។ បើមិនដូច្នោះទេ



ខ្ញុំនឹងប្តឹងពីអ្នកទៅតុលាការ ហើយបើសិនជាអ្នកប្រកែកពុំព្រមប្រាប់ខ្ញុំ, អ្នកមិនត្រឹមតែអស់សង្ឃឹមនិងខានទៅយករបស់នោះបានទៀតទេ គឺអ្នកថែមទាំងនឹងត្រូវបង់ខាតរបស់ទាំងប៉ុន្មាន ដែលអ្នកយកបានមកទៀតផង ។

អាលី-បាបា, តាមចរិតធម្មតាក៏ដូចជាតាមចិត្តទន់ខ្សោយរបស់វា, បានប្រាប់កាស៊ីមសព្វគ្រប់តាមបំណង គឺប្រាប់ទាំងពាក្យសម្រាប់ប្រើដើម្បីចូលនិងចេញពីរូងថ្មនោះផង ។

ឮតែប៉ុណ្ណេះ, កាស៊ីមក៏ឈប់សួរអ្វីទៀតទាំងអស់ ។ គាត់បែកចេញពីអាលី-បាបាភ្លាម, ចិត្តពោរពេញទៅដោយសេចក្តីសង្ឃឹមថានឹងទៅប្រមូលយកទ្រព្យប៉ុន្មានដែលនៅក្នុងឃ្លាំងនោះឱ្យអស់តែម្នាក់ឯង ។ ហេតុនេះស្អែកឡើងនៅពេលព្រលឹមធំមុនថ្ងៃរះ, គេឃើញគាត់ធ្វើដំណើរចេញពីផ្ទះតម្រង់ទៅទីឃ្លាំងជាមួយនឹងសត្វលា១០ ដែលផ្ទុកសុទ្ធតែហិបធំៗសម្រាប់យកទៅដាក់របស់ ។ គាត់យកហិបទៅជាច្រើនដូច្នេះ ដោយទុកបង្ការដល់ជើងទីពីរ គាត់នឹងបានផ្ទុកយករបស់ជាច្រើនបំផុត ដែលគាត់បានឃើញនៅក្នុងឃ្លាំងនោះ ។ មិនយូរប៉ុន្មានគាត់ក៏បានទៅដល់ផ្ទាំងសិលានោះ, ស្គាល់ច្បាស់នូវគ្រឿងសម្គាល់ នឹងដើមឈើដែលអាលី-បាបាពួន ។ គាត់ដើររកមាត់ទ្វារចូល, បានឃើញដូចចិត្ត រួចដើម្បីនឹងធ្វើឱ្យទ្វារនោះរបើក, គាត់ក៏ពោលថា "សេសាមចូរឯងបើក" ។ ទ្វារក៏របើក, គាត់ដើរចូល ទ្វារក៏បិទទៅវិញ ។ ឈរ

ពិនិត្យមើលរូងថ្មនោះទៅ, គាត់ក៏កើតក្តីអស្ចារ្យនឹងឃើញសម្បត្តិក្នុងនោះច្រើនគរគោកលើសពីបុរសអាលី-បាបា បាននិយាយប្រាប់ទៅទៀត ។ សេចក្តីអស្ចារ្យរបស់គាត់ក៏កាន់តែកើតមានធំឡើងៗ ដរាបណាដែលគាត់បានពិនិត្យឃើញមុខរបស់ដោយឡែកៗពីគ្នា ។ ជាជនកំណាញ់នឹងជាជនល្មោភសម្បត្តិស្រាប់ដូចជាខ្លួនគាត់, បើសិនជាគាត់កុំនឹកថា គាត់មកនេះដើម្បីនឹងយកមាសច្រកហិបផ្ទុកលើខ្នងលាគាត់ទាំង១០ នោះៗ គាត់មុខជានឹងនៅក្នុងកន្លែងនេះ អស់ពេលពេញមួយថ្ងៃ ដើម្បីនឹងចិញ្ចឹមភ្នែកគាត់ទៅលើតែគំនរមាស គាត់បានលើកជញ្ជូនយកមាសចេញជាច្រើនបារ, តែលុះមកដល់មាត់ទ្វារចេញ, គំនិតគាត់រវល់ជាប់ជំពាក់តែទៅលើគ្រឿងមាសប្រាក់កែវកងនោះខ្លាំងពេក, គាត់ក៏ភ្លេចពាក្យចាំបាច់សម្រាប់បើកទ្វារឈើងសូន្យទៅ ។ ដូច្នេះមិនថាសេសាម, គាត់បែរជាថា : “អ៊រ្ស៊ (Orge) [១] ចូរឯងបើក”, រួចគាត់ក៏មានសេចក្តីងឿងឆ្ងល់ថាក្រៃលែង ដោយឃើញទ្វារនៅតែបិទដដែល ។

កាស្សឹមក៏អស់សង្ឃឹមនឹងប្រព្រឹត្តការណ៍នេះ ។ នៅក្នុងគ្រោះ-

---

(១) កំណត់នៃអ្នកប្រែ: (Orge) បើប្រែមកជាខ្មែរ គឺជាពូកស្រូវបារាំង (ស្រូវសាឡី) ដូចគ្នានឹង (Sésame; សេសាម ប្រែថាល្ង, ប៉ុន្តែដោយនៅក្នុងរឿងនេះ, ពាក្យទាំងនេះសរសេរជាសាធារណនាម, ដូច្នេះ, សូមទុកជាភាសាគេដដែល ។ម្យ៉ាងទៀត, ក្នុងទីនេះបានជាបុរសកាស្សឹមនឹកឃើញពាក្យអ៊រ្ស៊មុនគេ ព្រោះចិត្តគាត់ជាប់ជំពាក់ទៅលើពាក្យថា អ៊រ (Or) ដែលប្រែមកជាខ្មែរថាមាស ។



គាត់មានហៅឈ្មោះធម្មជាតិជាច្រើនទៀត, ប៉ុន្តែទ្វារឥតព្រមបើកឡើយ ។ ថ្នាក់ដ៏ធំដូច្នេះ, សេចក្តីរន្ធត់ញាប់ញ័របានមកគ្របសង្កត់លើរាងកាយគាត់ ហើយល្ងីកណាគាត់ខំនឹករកពាក្យសេសាម, ល្ងីកនោះខួរក្បាល គាត់កាន់តែវង្វេងស៊ុងឡើងមួយសន្ទុះមក, ពាក្យនោះលែងធ្វើឱ្យគាត់នឹកប្រហាក់ប្រហែលស្រមៃឃើញបន្តិចឡើយ, ហាក់ដូចជាគាត់ឥតដែលបានឮគេនិយាយសោះ ។ គាត់បានគ្រវាត់គ្រវែងចោលបារទាំងឡាយដែលនៅនឹងខ្លួនគាត់ ។ រួចក៏ដើរឈានជើងវែងៗនៅក្នុងរូងថ្មម្តងទៅខាងនេះ ម្តងទៅខាងនោះ, ហើយទ្រព្យសម្បត្តិដែលនៅជុំវិញ ខ្លួនគាត់ឥតប៉ះទង្គិចគាត់ឡើយ ។ យើងសូមទុកបុរសកា-ស្សឹមឱ្យនៅទួញសោកតាមយថាកម្មរបស់គាត់ក្នុងទីនេះចុះ ព្រោះរឿងគាត់មិនត្រូវឱ្យគេអាណិតទេ ។

ដំណាលពីពួកចោរទាំងឡាយវិញ, វាបានត្រឡប់មកជម្រកវាវិញនៅពេលថ្ងៃត្រង់ជាក់ ។ កាលបើវាមកដល់ជិតរូងថ្ម និងកាលបើវាបានឃើញលារបស់កាស្សឹមនៅជុំវិញរូងថ្ម មានផ្ទុកសុទ្ធតែហិបនៅលើខ្នង, វាក៏មានសេចក្តីចាប់អារម្មណ៍នឹងព្រឹត្តិការណ៍ថ្មីនេះណាស់, ទើបបបួលគ្នាជិះសេះបំផាយយ៉ាងលឿនតម្រង់មកទីនោះ, បណ្តាលឱ្យលាកាស្សឹមដែលគាត់ចងចោល បោលរប៉ាត់រប៉ាយពាសពេញក្នុងព្រៃខ្លះបោលទៅខាងនេះ ខ្លះបោលទៅខាងនោះបាត់អស់ ។

ឯពួកចោរឥតរវល់នឹងជិះសេះដេញតាមលាទាំងនោះទេ, វា

គិតតែពីរកមើលម្ចាស់សត្វនោះវិញ ។ នៅពេលដែលពួកចោរខ្លះ កំពុងតែបរសេះក្រឡឹងរូងថ្ម, មេចោរដែលនៅជាមួយនឹងកូនចោរខ្លះទៀតក៏ចុះពីខ្នងជំនិះ រួចដើរតម្រង់ទៅមាត់ទ្វាររូង, ដៃកាន់កាំបិតស្នៀតសស្វាច រួចពោលពាក្យពិសេសឡើង ទ្វារក៏របើកភ្លាម ។

កាស៊ីម, ដែលបានឮសូរជើងសេះចំពីលើពាក់កណ្ដាលរូង ក៏ដឹងដោយឥតសង្ស័យថា ពួកចោរត្រឡប់មកវិញហើយ, ឯខ្លួនក៏នឹងត្រូវស្លាប់ជាពុំខាន ។ ដូច្នេះ គាត់ក៏ទៅពួនចាំត្រង់មាត់ទ្វារចូល, ដើម្បីស្ទុះចេញទម្លាយពួកចោរ រត់គេចឱ្យតែរួចព្រះអាយុ នៅពេលដែលទ្វារថ្មរបើកកាលណា ។ កាលបើទ្វាររបើកភ្លាម, គាត់ក៏ស្ទុះបោះពួយចេញពីក្នុងរូងយ៉ាងរហ័សបំផុត, ធ្វើឱ្យមេចោរដួលបះជើងច្រងាងដាំដូងដាំទីងទៅលើដី ។ ប៉ុន្តែជាអភ័ព្វគាត់ពុំអាចរត់ផុតពីកណ្ដាប់ដៃនៃពួកចោរឯទៀត ដែលសុទ្ធតែមានកាំបិតស្នៀតកាន់នៅដៃ ។ ពួកចោរទាំងនោះបានផ្ដាច់ផ្ដិលជីវិតគាត់មួយរំពេច ។

កិច្ចជាបឋមនៃពួកចោរ បន្ទាប់ពីការប្រតិបត្តិការនោះមក គឺបបួលគ្នាចូលទៅក្នុងរូងថ្ម ។ វាបានឃើញបាវជាច្រើននៅជិតមាត់ទ្វារដែលកាស៊ីមលើកជញ្ជូនមកដាក់ប្រយោជន៍យកចេញទៅផ្ទុកលើខ្នងលាគាត់ ។ ពួកចោរក៏បបួលគ្នាលើកជញ្ជូនរបស់នោះទៅដាក់កន្លែងដើមវិញ ដោយឥតមានដឹងថា បាត់បាវខ្លះ ដែលអាលី-បាបាបានលួចយកពីពេលមុននោះទេ ។ លុះប្រជុំគ្នាពិភាក្សាប្តូរយោបល់គ្នាទៅវិញ



ទៅមកពីព្រឹត្តិការណ៍នេះទៅ, វាក៏បានយល់នូវរបៀបដែលកាស៊ីមចេញពីរូងថ្ម, ប៉ុន្តែវាពុំអាចយល់បានថា តើកាស៊ីមចូលមកតាមណា ។ សំនួរនេះពុំអាចធ្វើឱ្យវាស្មានដូចម្ដេចបានឡើយ ។ គំនិតមួយបានលេចឡើងថា ប្រហែលជាជននោះចូលមកតាមប្រហោងពីលើ ។ ប៉ុន្តែប្រហោងដែលសម្រាប់ពន្លឺថ្ងៃចេញចូលនោះនៅខ្ពស់ណាស់, ហើយគ្មាននរណាអាចឡើងទៅរួចផង ។ ក្រៅពីនោះ, គ្មានអ្វីអាចឱ្យពួកចោរសម្គាល់ឃើញយ៉ាងណាៗឡើយ គឺវាទាល់តម្រិះនឹងគិតតទៅទៀត ។ បើដូច្នេះមានតែជននោះចូលតាមមាត់ទ្វារ, ប៉ុន្តែ បើវាចូលតាមទ្វារបានលុះត្រាតែវាដឹងការអាថិកំបាំង ទើបបើកទ្វារបាន រឿងត្រង់នេះពួកចោរពុំព្រមជឿសោះឡើយ ។ ពួកចោរទាំងនោះជឿជាក់ក្នុងខ្លួនថា មានតែពួកខ្លួនទេដែលដឹងការសម្ងាត់នេះ, វាពុំដឹងថា ការសម្ងាត់នេះត្រូវត្រចៀកអាលី-បាបា ស្រូបយកឡើយ ។

ពួកចោរទាំងអស់គ្នាក៏គិតថា ណ្ហើយទោះរឿងនេះកើតមានមកយ៉ាងដូចម្ដេចក៏ដោយ, ក៏យើងត្រូវឈប់ស្ដេះទៅ ព្រោះទ្រព្យសម្បត្តិយើងទាំងឡាយនៅជាប្រក្រតី ។ យើងត្រូវបបួលគ្នាកាត់សពកាស៊ីមនេះជាបួនកំណាត់ រួចយកទៅដាក់ក្បែរមាត់ទ្វារពីខាងក្នុងពីរកំណាត់ម្ខាងៗ ប្រយោជន៍នឹងបន្លាចដល់ជនអ្នកក្លាហានណា ដែលហ៊ានចូលមកទីនេះធ្វើកិច្ចដូច្នេះទៀត ។ យើងនឹងត្រឡប់មកកាន់ទីរូងនេះវិញ បន្ទាប់ពេលដែលសាកសពនេះនឹងធុំក្លិនស្អុយ ។ គិតដូច្នោះ

ហើយ. ពួកចោរទាំងឡាយក៏ចាប់ផ្ដើមប្រតិបត្តិការ ។ លុះអស់កិច្ចអ្វីទៀតហើយ ពួកចោរហានេយ្យំនោះក៏ទាញទ្វារបិទយ៉ាងជិតហើយឡើងជិះសេះបរទៅតាមផ្លូវ ដែលពួកទូរចរតែងឆ្លងកាត់ចុះឡើងញឹកញាប់ ដើម្បីចាំវាយប្រហារពួកនោះតាមទម្លាប់ការលួចប្លន់របស់វារៀងមក។

ពោលពីប្រពន្ធកាស្សីមវិញ. គាត់មានសេចក្ដីអន្ទះសាជ្រួលច្របល់ក្នុងចិត្តជាក្រៃលែង កាលបើរាត្រីងងឹតឈឹងសូន្យមកពាសលើផ្ទៃប្រថពីហើយៗគាត់ពុំទាន់ឃើញប្ដីគាត់ត្រឡប់មកវិញផង ។ គាត់រត់ឆ្លេឆ្លាទៅផ្ទះអាលី-បាបាហើយនិយាយថា : "នែប្អូនអើយ ឯងក៏បានដឹងដែរថា កាស្សីមបងឯងបានចេញទៅព្រៃដើម្បីរឿងអ្វីនោះ ឥឡូវពុំទាន់ឃើញគាត់ត្រឡប់មកវិញសោះ ហើយយប់ក៏កាន់តែជ្រៅណាស់ទៅហើយ បងបារម្ភក្រែងមានគ្រោះចង្រៃអ្វីកើតមានដល់រូបគាត់ " ។

កាលបើឮបងថ្លៃគាត់រាប់រៀបដូច្នេះ. អាលី-បាបាក៏នឹកសង្ស័យនឹងដំណើររបស់បងគាត់នេះ។ អាស្រ័យហេតុនេះហើយ បានជានៅថ្ងៃនោះ អាលី-បាបា ឥតចេញទៅព្រៃឡើយ ដើម្បីដល់មានរឿងអ្វីឡើងកុំឱ្យគេមន្ទិលដល់ខ្លួន ។ ដោយឥតមានស្ដីឬបន្ទោសអ្វីបន្តិចទៅបងថ្លៃវិញ. ព្រោះការស្ដីបន្ទោសជាហេតុនាំឱ្យគាត់ និងប្ដីគាត់មានការអាក់អន់ចិត្ត បើសិនជាប្ដីគេនៅរស់វិញ វាបានឆ្លើយទៅវិញដូច្នេះថា សូមអ្នកបងកុំទាន់អាលភ័យអ្វី. តាមខ្ញុំស្មានទៅ បងកាស្សីម គាត់សុទ្ធតែ



បានគិតស្រេចហើយថា គាត់នឹងត្រឡប់ចូលមកទីក្រុងនៅវេលាយប់ជ្រៅបំផុត ។

ប្រពន្ធកាស្សីមក៏ព្រមជឿតាមដូច្នេះ. ហើយគាត់បែរជានឹកឃើញថា ស្វាមីគាត់ប្រាកដជាមានការអាថ៌កំបាំងយ៉ាងសំខាន់បំផុតហើយ ។ គាត់ក៏ត្រឡប់ទៅផ្ទះវិញ. អង្គុយចាំមើលផ្លូវប្ដីអភ័ព្វរបស់គាត់ លុះត្រាដល់ពេលកណ្ដាលអធ្រាត្រ ។ លុះបន្ទាប់ពីនោះមក. ការភ័យអាសន្នរបស់គាត់ក៏ទ្វេឡើងមួយជាពីររកតែស្រែក ឬពោលសម្រាលទុក្ខថាដូចម្ដេចពុំបានឡើយ ។ គាត់យល់ច្បាស់ថា រឿងហេតុនេះត្រូវអ្នកជិតខាងគេលាក់មិនឱ្យនិយាយ ដូច្នេះបើសិនជាកំហុសរបស់គាត់ពុំអាចកែវិញបានទេ. នោះគាត់មានវិប្បដិសារីសោកស្ដាយជាក្រៃលែងនឹងមារយាទឆ្កួតចង់ឃើញការអ្វីៗ ឥតបើពិចារណា. ហើយកំហុសនេះបណ្ដាលមកតែអំពីគាត់មានចិត្តលោភលន់ខ្លាំងពេក ចូលទៅជ្រៀតជ្រែកកិច្ចការព្វដ៏ខាងក្នុងនៃប្អូនថ្លៃប្រុសនិងប្អូនថ្លៃស្រីរបស់គាត់ ។ ក្នុងរាត្រីនោះគាត់ដេកប្រឡែងតែជាមួយនិងទឹកភ្នែក លុះព្រះអាទិត្យទឹមព្រះរាជរថ ចេញបំភ្លឺសត្វលោកឡើងកាលណា គាត់ក៏រត់រលះ-រលាំងរឃីករយាកតម្រង់ទៅផ្ទះប្អូនទាំងពីរ ហើយចរចារឿងរ៉ាវដែលបណ្ដាលឱ្យគាត់មកកាន់ទីនេះទៀត ប្រាប់ដោយទឹកជលនេត្រ ព្រោះគាត់ពុំអាចនិយាយអ្វីបានឡើយ ។

អាលី-បាបា ឥតបង្អង់ចាំឱ្យបងស្រីអង្វរខ្លួនឱ្យទៅតាមរក

មើលបងទាន់ឡើយ, វាក៏រៀបដំណើរចេញទៅព្រៃមួយរំពេច ជាមួយនឹងសត្វលាបីបន្ទាប់ពីបានជួយរំលឹកបងស្រី កុំឱ្យសោកសង្រេងខ្លាំងពេក ។ កាលបើបានទៅដល់ជិតរូងថ្មភ្លាម បន្ទាប់ពីធ្វើដំណើរតាមផ្លូវដោយឥតមានជួប ឬឃើញបងវានិងលាទាំង ១០នោះ, វាក៏ភ្ញាក់ខ្លួនក្រញាងដោយឆ្ងល់នឹងលោហិតដែលប្រឡាក់ក្រាលនៅលើដីជិតមាត់ទ្វារ, វាទុកការណ៍នេះជាប្រផ្នូលអាក្រក់មួយ, វាក៏ទៅជិតមាត់ទ្វារ, ពោលពាក្យពិសេសទ្វារក៏របើកភ្លាម ។ បេះដូងវាក៏ញ័ររន្ធត់នឹងទស្សនីយភាពនៃរូបបងវា ដែលត្រូវគេកាត់ជាបួនកំណាត់ ។ វាក៏ឥតមានស្ទាក់ស្ទើរចិត្តនឹងចូលទៅបំពេញករណីយកិច្ច ដែលវាត្រូវមានចំពោះបងនៅពេលជាលើកក្រោយបំផុតនេះដែរ ទោះបើដឹងថាភាតរភាពរវាងវា និងបងវានៅមានតែបន្តិចបន្តួចក៏ដោយ ។ វាខំដើររកវត្ថុក្នុងរូងនោះមកខ្ចប់សពបងគាត់ជាពីរកំណាត់, រួចយកទៅដាក់លើខ្នងលាមួយទើបយកឧសផ្ទុកពីលើថែមទៀត ដើម្បីកុំឱ្យគេឃើញវត្ថុនោះ ។ ចំណែកឯលាពីរទៀត, វាផ្ទុកសុទ្ធតែបាវមាស ហើយយកឧសដាក់ពីលើដូចកាលលើកទីមួយ ដោយឥតបង្អង់ឱ្យយឺតយូរពេលឡើយ ។ លុះរៀបចំរួចស្រេចបាច់ហើយៗបានបង្គាប់ទ្វារឱ្យបិទទៅវិញ, វាក៏បរលាតម្រង់ទៅទីក្រុងវិញ ។ ប៉ុន្តែវាមានការប្រយ័ត្នប្រយែងណាស់ គឺត្រូវទៅឈប់នៅមាត់ផ្លូវចេញពីព្រៃ, រង់ចាំដល់ពេលយប់ទើបចូលទៅផ្ទះ។ លុះទៅដល់ផ្ទះវាបញ្ចូលតែលាពីរ ដែលផ្ទុកមាសទៅក្នុងផ្ទះវា។



រួចក្រោយពីប្រាប់ឱ្យប្រពន្ធវារើយករបស់នោះទុករួចនឹងនិយាយរឿងកាសុីមប្រាប់ពីរបីម៉ាត់នោះ វាក៏នាំលាមួយទៀតតម្រង់ទៅផ្ទះបងថ្លៃស្រី ។

អាលី-បាបា បានគោះទ្វារផ្ទះហៅ, នាងមរ្សៀយ៉ាន (Morgiane) ក៏ចេញមកបើកទ្វារឱ្យ ។ មរ្សៀយ៉ានជាទាសីមួយរូបឆ្លាតប្រសប់, ឆាប់យល់កិច្ចការប្រកបដោយតក្កវិទូ អាចធ្វើឱ្យសម្រេចនូវឧបសគ្គដ៏ធំៗទាំងឡាយ ។ ហើយអាលី-បាបា ក៏បានស្គាល់នាងដោយសារតែការណ៍ដូច្នេះ ។ លុះចូលទៅដល់ទីធ្លា, អាលី-បាបាក៏ស្រាយឧសនឹងកញ្ចប់ពីរចេញពីខ្នងលា, រួចដឹកដៃមរ្សៀយ៉ានទៅខ្សឹបថា : «មរ្សៀយ៉ាន រឿងជាបឋមដែលខ្ញុំត្រូវការនិយាយនឹងឯង គឺការអាថ៌កំបាំងដែលគ្មាននរណាគេចផុតបាន ។ ឯងនឹងបានឃើញថា តើរឿងនោះជាការចាំបាច់ដល់យើងយ៉ាងណា គឺដល់រូបចៅហ្វាយឯង ក៏ដូចជាដល់រូបខ្ញុំដែរ ។ នុះហ្ន៎ ! នៅក្នុងកញ្ចប់ពីរនោះហើយដែលជាខ្លួនរបស់ចៅហ្វាយប្រុសឯង ។ យើងត្រូវយករូបគាត់នោះទៅកប់ ធ្វើហាក់ដូចជាគាត់ស្លាប់ដោយជម្ងឺធម្មតា ។ ចូរឯងនាំយើងទៅជួបនិយាយគ្នានឹងចៅហ្វាយស្រីឯងបន្តិច, ហើយចូរឯងប្រុងស្មារតីចាំស្តាប់ឱ្យមែនទែននូវគ្រប់កិច្ចការ ដែលខ្ញុំនឹងត្រូវនិយាយប្រាប់គាត់» ។

មរ្សៀយ៉ាន ក៏ទៅប្រាប់ចៅហ្វាយស្រីខ្លួន ។

អាលី-បាបា ដែលដើរពីក្រោយក៏ចូលទៅតាម ។

បងថ្លៃវាក៏សួរមកវាដោយទឹកមុខក្រៀមក្រំថា :

“ម៉ែចទៅអូន. អូនឯងបានដំណឹងអ្វីពីប្ដីបងមកប្រាប់បង? បងឥតសម្លឹងឃើញទឹកមុខអូនឯងត្រង់ណា ដែលអាចជួយលួងលោមចិត្តបងបានទេ ។

- អ្នកបង. (អាលី-បាបា ឆ្លើយ) ខ្ញុំគ្មានរឿងអ្វីនឹងនិយាយប្រាប់បងឡើយ ។ បើសិនជាមិនព្រមសន្យានឹងស្ដាប់រឿងប្អូនតាំងពីដើមដល់ចប់. ដោយឥតហើបមាត់ថាអ្វីបន្តិចឡើយ ។ រឿងនោះមិន-មែនសារសំខាន់តិចតួចឡើយ ដល់រូបបងនិងខ្ញុំ ដែលត្រូវលាក់មហាអាថិកំបាំងនេះ ដើម្បីជាសម្បត្តិដល់អ្នកបងក៏ដូចជាដល់រូបខ្ញុំ ។

- ពុទ្ធោអើយ. ប្រពន្ធកាស៊ីមស្រែកភ្ញាត់សម្លេង. សេចក្ដីផ្ដើមរបស់អូនឯងនេះ ធ្វើឱ្យបងយល់ថាប្ដីបងឥតមានជីវិតរស់នៅក្នុងលោកនេះទេ ប៉ុន្តែក្នុងពេលជាមួយគ្នានេះ. បងក៏ស្គាល់នូវការអាថិកំបាំងជាការចាំបាច់ដែលប្អូនសុំឱ្យបងធ្វើនោះដែរ ។ បងស៊ូតែខំអត់សង្កត់ចិត្ត ដូច្នេះចូរអូននិយាយប្រាប់បងមក បងនឹងស្ដាប់ ។

អាលី-បាបា ក៏ចាប់ផ្ដើមនិយាយរឿងតាំងពីចេញដំណើរទៅបានលទ្ធផលយ៉ាងណា. រហូតទល់នឹងត្រឡប់មកវិញបាន ទាំងខ្លួនកាស៊ីមឱ្យបងថ្លៃស្ដាប់ ។

- អ្នកបង. (អាលី-បាបា បន្ថែម). នេះហើយជាមេរឿងនៃទុក្ខរបស់អ្នកបង ពិតមែនតែការឈឺចាប់នេះគ្មានឱសថអ្វីនឹងដាក់ឱ្យ



ជាបានឡើយ. ប៉ុន្តែខ្ញុំមានវត្ថុមួយអាចជួយលួងលោមអ្នកបងបាន គឺខ្ញុំសូមជូនរបស់ទ្រព្យទាំងប៉ុន្មាន ដែលព្រះអាទិទេពបានផ្ដល់ឱ្យៗទៅជាសម្បត្តិរបស់អ្នកបងវិញ ដោយរៀបការជាមួយនឹងអ្នកបង. ហើយខ្ញុំសូមធានាជូនថាប្រពន្ធខ្ញុំនឹងឥតមានចិត្តច្រណែន ហើយយើងនឹងរស់នៅទាំងអស់គ្នាដោយសិរីសួស្ដីតទៅ ។ បើសិនជាការស្នើរបស់ខ្ញុំត្រូវចិត្តអ្នកបងដែរ. យើងត្រូវគិតយ៉ាងណាឱ្យគេដឹងព្វថា បងស្លាប់ដោយសារការស្លាប់ធម្មតា ។ តាមខ្ញុំយល់ការណ៍នេះ អ្នកបងត្រូវពឹងផ្អែកទៅលើមរ្យ៉ាន ។ ចំណែកខ្ញុំៗនឹងខំប្រឹងពេញទំហឹងតាមសមត្ថភាពដែលអាចធ្វើបាន ។

តើឱ្យស្រីមេម៉ាយកាស៊ីមរើសយកផ្លូវណាវិញ ក្រៅពីផ្លូវដែលអាលី-បាបាបានស្នើនោះ ខ្លួនគាត់មានសល់ទ្រព្យសម្បត្តិខ្លះពីខ្មោចប្ដីគាត់ទីមួយមែន តែគាត់សម្លឹងឃើញជនម្នាក់ទៀត មានជាងគាត់ទៅទៀត. ដោយសារគេបានរកឃើញឃ្លាំងមាស ឃ្លាំងប្រាក់ តើទ្រព្យខាងក្រោយនេះអាចធ្វើឱ្យគាត់ទៅជាអ្នកមានលើសនេះទៀតបានទេ? ស្រីមេម៉ាយឥតប្រកែកឡើយ ។ ផ្ទុយទៅវិញ. គេសម្លឹងឃើញថានេះជារឿងមួយយ៉ាងសមហេតុសមផលអាចជួយសម្រាលទុក្ខគេបាន។ ក្រោយពីបានយកដៃជូតទឹកភ្នែកដែលបានហូរធ្លាក់សស្រាក់មកជាច្រើនគ្រាប់នោះ និងក្រោយពីបញ្ឈប់សម្រែកទួញសោកអាឡោះអា-ល័យ ដែលជាសម្រែកធម្មតានៃស្ត្រីភេទទាំងឡាយ ដែលត្រូវប្រាស់

ចាកស្វាមីជាទីស្នេហារបស់គេ, ប្រពន្ធខ្មោចកាស៊ីមក៏សំដែងអាកប្ប-កិរិយាទៅកាន់ អាលី-បាបា ជាការបញ្ជាក់ឱ្យដឹងថា គាត់ព្រមទទួលនូវអំណោយរបស់អាលី-បាបាហើយ ។

អាលី-បាបា ក៏បានទុកស្រីមេម៉ាយនៃខ្មោចលោកកាស៊ីមនៅក្នុងស្ថានភាពដូច្នេះសិនចុះ ។ ហើយបន្ទាប់ពីវាបានផ្ដែផ្ដាំទៅនាងមរ្ស៊ីយ៉ាន ឱ្យខំយកចិត្តទុកដាក់បំពេញកិច្ចនេះតាមបុគ្គលិកលក្ខណៈរបស់ខ្លួនឱ្យមែនទែន វាក៏ត្រឡប់ទៅផ្ទះវិញជាមួយនឹងលាវ៉ា ។

មរ្ស៊ីយ៉ានឥតមានភ្លេចភារៈរបស់ខ្លួនឡើយ ។ ដំណាលគ្នានឹងអាលី-បាបាដែរ, នាងចេញពីផ្ទះតម្រង់ទៅឱសថស្ថានដែលនៅជិតនោះ ។ នាងទៅគោះទ្វារផ្ទះ, គេក៏បើកឱ្យ ។ នាងក៏សួររកថ្នាំលេបមួយយ៉ាងស័ក្តិសិទ្ធបំផុត ដែលសម្រាប់ជួយសង្គ្រោះជំងឺដែលដាបខ្លាំងជាទីបំផុត។ ឱសថការីក៏យកថ្នាំឱ្យតាមចំនួនលុយដែលនាងបានបង្ហាញហើយគេក៏សួរមកនាងថា តើនរណាឈឺនៅឯផ្ទះចៅហ្វាយនាង ។

“ចាំ, គឺលោកកាស៊ីមចៅហ្វាយដ៏ប្រសើររបស់ខ្ញុំនេះឯង, នាងឆ្លើយដោយដកដង្ហើមធំ។ គ្មាននរណាបានដឹងថា គាត់ឈឺឡើយ, គាត់អត់និយាយ ហើយឥតទទួលទានបាយបន្តិចសោះ” ។

ពោលដូច្នោះរួច, នាងក៏កាន់ថ្នាំនោះចេញទៅដែលតាមពិតកាស៊ីមមិនអាចនឹងប្រើប្រាស់ថ្នាំនោះបានឡើយ ។

ថ្ងៃស្អែកឡើង, នាងមរ្ស៊ីយ៉ានក៏ទៅកាន់ផ្ទះឱសថការីដដែល



ទៀត, ប្រកបដោយអស្សុជលនេត្រពោរពេញថ្ពាល់, សួររកទឹកថ្នាំម្យ៉ាងដែលគេតែងឱ្យមនុស្សជំងឺផឹក នៅពេលខាងក្រោយបំផុតនៃអាយុសង្ខារ ។ ហើយគេនឹងអស់សង្ឃឹមថា អ្នកជំងឺនឹងមានជីវិតរស់រានវិញឡើយ, បើសិនជាថ្នាំខាងក្រោយនេះគ្មានឱ្យលទ្ធផលអ្វីនោះ ។

“ឱម្ចាស់ថ្លៃអើយ ! នាងពោលដោយសោកសង្រេងនៅពេលទទួលយកថ្នាំពីដៃនាយឱសថស្ថាន ខ្ញុំបារម្ភណាស់ ក្រែងថ្នាំនេះគ្មានឱ្យផលអ្វីដូចជាថ្នាំគ្រាប់ទៀត ! ឱ, ពេលនេះខ្ញុំនឹងព្រាត់ចៅហ្វាយដ៏ប្រសើររបស់ខ្ញុំហើយ” ។

មួយចំណែកទៀត, ក្នុងមួយថ្ងៃៗ វាល់ល្ងាចគេឃើញអាលី-បាបា និងប្រពន្ធចុះឡើងៗទៅមកផ្ទះកាស៊ីមឥតឈប់ឈរ ។ ការណ៍នេះគេឥតឆ្ងល់ឡើយ, ព្រោះនៅវេលាល្ងាចថ្ងៃនោះ គេឮសូរសម្រែកទួញនៃប្រពន្ធកាស៊ីម, ពិសេសគឺនាងមរ្ស៊ីយ៉ានជាហេតុឱ្យដឹងថាកាស៊ីមបានចាកឋានមនុស្សលោកយើងនេះទៅហើយ ។

ថ្ងៃជាបន្ទាប់មក, នៅពេលព្រលឹមធំដែលព្រះអាទិត្យទើបនឹងចាប់បញ្ចាំងរស្មីឡើងបន្តិច, នាងមរ្ស៊ីយ៉ានដែលបានដឹងថា នៅក្នុងភូមិភាគនេះមានជាងដេរស្បែកជើងម្នាក់មានវ័យចំណាស់ណាស់ទៅហើយៗគាត់តែងបើកទ្វារផ្ទះធ្វើការមុនគេយ៉ាងយូរផងជារៀងរាល់ថ្ងៃជានិច្ច, ក៏ចេញពីផ្ទះទៅជួបនឹងគាត់ លុះចូលទៅជិតគាត់នឹងជម្រាបសួរគាត់រួច នាងក៏ដាក់លុយមាសមួយដុំទៅក្នុងដៃគាត់ ។

បាបា-មុស្តាហ្វា (Baba-moustafa), នេះជាឈ្មោះជាងដេរស្បែកជើង ដែលគេស្គាល់ស្ទើរតែគ្រប់គ្នា ។ បាបា-មុស្តាហ្វាជាមនុស្សសប្បាយធម្មតា គាត់តែងមានពាក្យពោល ដើម្បីសើចលេងជានិច្ច ។ ដោយព្រះអាទិត្យពុំទាន់រះពេញវង់ស្រួល, គាត់ខំផ្ទៀងសម្លឹងមើលលុយមាស លុះស្គាល់ច្បាស់ថាជាមាសហើយ, គាត់ក៏ពោលឡើងថា : "រង្វាន់ដ៏ប្រសើរសម្រាប់ឆ្នាំថ្មី, តើនាងមានការអ្វី? ខ្ញុំបានប្រុងប្រៀបខ្លួននឹងធ្វើជូនហើយ" ។

- បាបា-មុស្តាហ្វា (នាងមរ្យ៉ៀានចរចា), សូមលោកតាអញ្ជើញយកថ្លៃសម្រាប់ជួលដេរនេះទៅ រួចសូមអញ្ជើញមកតាមខ្ញុំយ៉ាងរួសរាន់បន្តិច, ប៉ុន្តែខ្ញុំនឹងរុំបិទភ្នែកលោកតា កាលបើយើងទៅដល់កន្លែងមួយ ។

កាលបើឮដូច្នេះ, ជាងដេរស្បែកជើងក៏រុញរាចិត្ត រួចពោលថា: "យី ! យី ! ម៉ែអើយ ! នាងចង់ប្រើខ្ញុំធ្វើអ្វីផ្ទុយនឹងសម្បជញ្ញៈ ឬនឹងកិត្តិយសរបស់ខ្ញុំឬ" ។

នាងមរ្យ៉ៀានក៏ដាក់លុយមាសមួយដុំទៀតទៅក្នុងដៃគាត់ ហើយស្រដីថា: "សូមលោកតាកុំភ័យឱ្យសោះការដែលខ្ញុំសូមឱ្យលោកតាធ្វើនេះ, គឺធ្វើដោយពេញកិត្តិយសលោកតា, សូមឱ្យតែលោកតាអញ្ជើញទៅ"

បាបា-មុស្តាហ្វា ក៏ព្រមទៅតាមនាង ។ នាងមរ្យ៉ៀាន ក្រោយ



ពីបានយកកន្សែងរុំមុខគាត់នៅត្រង់កន្លែង ដែលនាងបានគិតទុកហើយក៏នាំមុស្តាហ្វាតម្រង់ទៅផ្ទះខ្មោចចៅហ្វាយនាង ។ នាងបានស្រាយកន្សែងចេញពីភ្នែក ជាងដេរស្បែកជើងលុះត្រាតែបានចូលទៅដល់ក្នុងបន្ទប់ ដែលដាក់សពចៅហ្វាយនាងជាប្អូនកំណាត់ ។ លុះស្រាយកន្សែងចេញពីភ្នែកជរាជនហើយ នាងក៏បន្លឺវាចាថា : "...ដែលខ្ញុំនាំលោកតាមកនេះ គឺដើម្បីឱ្យលោកតាដេរដុំបួននៅមុខលោកតានេះឱ្យបានជាប់គ្នា ។ សូមកុំបង្អង់យូរឱ្យសោះ ។ កាលបើលោកតាធ្វើហើយខ្ញុំនឹងជូនលុយមាសមួយដុំទៀត" ។

កាលបើ បាបា-មុស្តាហ្វា, បំពេញកិច្ចគាត់រួច នាងទាសីក៏រុំមុខគាត់នៅក្នុងបន្ទប់នោះវិញ, រួចក្រោយពីឱ្យលុយ ដែលបានសន្យានឹងគាត់មួយដុំទៀត នឹងក្រោយពីបានហាមគាត់កុំឱ្យនិយាយរឿងនេះប្រាប់នរណាឱ្យសោះ, នាងក៏ជូនគាត់ទៅដល់កន្លែង ដែលនាងបានរុំមុខគាត់នៅពេលនាំមក ។ ទៅដល់កន្លែងនោះ, នាងក៏ស្រាយមុខគាត់ចេញហើយក៏បើកឱ្យគាត់ត្រឡប់ទៅផ្ទះវិញទៅ ។ ប៉ុន្តែនាងនៅឈរសម្លឹងមើលគាត់ លុះត្រាតែផុតកន្ទុយភ្នែកដើម្បីឱ្យអស់សង្ស័យ ក្រែងគាត់ត្រឡប់មកតាមមើលនាងវិញ ។

នាងមរ្យ៉ៀាន បានដាំទឹកក្តៅដើម្បីចំអាសសពលោកកាស៊ីម ។ ដូច្នេះអាលី-បាបា ដែលទើបនឹងមកដល់ក្រោយនាងបន្តិចនេះដែរ ក៏យកទឹកក្តៅចំអាសបុគ្គល លាបគ្រឿងក្រអូប, រួចរុំក្រណាត់ ព្រមទាំង

ធ្វើពិធីផ្សេងៗតាមទម្លាប់ ។ ជាងឈើក៏យកក្ដារមឈូស ដែលអាលី-បាបាជួលឱ្យធ្វើមកដល់ ។

ដើម្បីកុំឱ្យជាងឈើឃើញអ្វីទាំងអស់, នាងមរ្ជីយ៉ានបានទៅទទួលយកក្ដារមឈូសពីមាត់ទ្វារផ្ទះ បន្ទាប់ពីចេញលុយឱ្យគេ និងប្រាប់គេឱ្យត្រឡប់ទៅវិញចុះ, នាងក៏ចូលទៅជួយ អាលី-បាបាលើកសពដាក់ទៅក្នុងក្ដារ ។ បន្ទាប់ពី អាលី-បាបាយកបន្ទះក្ដារវាយលើក្ដារមឈូសជិតហើយ, នាងក៏ទៅកាន់ព្រះវិហារមហាម៉ាត់ប្រាប់ថា ការកប់សពបានរៀបចំជាស្រេចហើយ ។ ពួកជននៅក្នុងព្រះវិហារដែលជាអ្នកចំអាសសពក៏ព្រមព្រៀងគ្នាថា នឹងមកបំពេញមុខការ, ប៉ុន្តែនាងបានប្រាប់ថា កិច្ចនេះគេបានធ្វើស្រេចទៅហើយ ។

ត្រឡប់មកផ្ទះវិញ នាងគ្មានធ្វើអ្វីទៀតក្រៅពីចាំនិមន្តលោកគ្រូសង្ឃរាជ និងលោកសង្ឃឯទៀតចូលទៅក្នុងផ្ទះឡើយ ។ អ្នកជិតខាងបួននាក់ក៏សែងក្ដារមឈូសដើរតាមលោកគ្រូសង្ឃរាជ ដែលសូត្រធមិបណ្ដើរ គេសែងក្ដារមឈូសតម្រង់ទៅទីកប់ខ្មោច ។ ជាទាសីនៃសព ។ នាងមរ្ជីយ៉ានទួញសោកដើរតាមក្រោយ, ក្បាលទទេ, យកដៃតប់ទះទ្រូងទាញកន្ត្រាក់សក់ក្បាល ។ ឯអាលី-បាបាដើរពីក្រោយជា-មួយនឹងក្រុមញាតិជិតខាង, ដែលយូរៗ គេបែកគ្នាម្ដង ដើម្បីរត់ទៅជួយផ្លាស់គ្នាសែងក្ដារទម្រាំនឹងទៅដល់ទីប៉ាឆា ។

ចំណែកប្រពន្ធកាស៊ីមវិញ គាត់នៅឯផ្ទះយំទួញសោកបោក



ខ្លួន រាប់រៀបគ្រប់សព្វអាឡោះអាល័យប្ដីជាមួយនឹងប្រពន្ធអ្នកជិតខាង ព្រោះជាទំនៀម, នៅពេលធ្វើបុណ្យកប់ខ្មោចម្ដងៗ, ប្រពន្ធអ្នកជិតខាងតែងរត់ទៅជួយយំសោក ប្រពន្ធអ្នកមានទុក្ខ ។ សម្លេងទុក្ខព្រួយនោះក៏លាន់ឮពេញសង្កាត់និងទីឆ្ងាយៗនៅជុំវិញ ។

អាស្រ័យហេតុនេះ, មរណភាពដ៏អពមង្គលនៃបុរសកាស៊ីម, ក៏ត្រូវ អាលី-បាបា ប្រពន្ធ, នាងមេម៉ាយកាស៊ីម នឹងនាងមរ្ជីយ៉ានលាក់បាត់, ដោយប្រើមធ្យោបាយចាត់ចែងការយ៉ាងប្រពៃ សូម្បីតែជនម្នាក់ក្នុងទីក្រុង ក៏គ្មានការចាប់ភ្លឹកនឹកសង្ស័យអ្វីបន្តិចសោះឡើយ ។

ពីរបីថ្ងៃបន្ទាប់ពីថ្ងៃធ្វើបុណ្យកប់ខ្មោចកាស៊ីមមក, អាលី-បាបា ក៏បានជញ្ជូនគ្រឿងសង្ហារិមបន្តិចបន្តួចពីផ្ទះវា ទៅផ្ទះស្រីមេម៉ាយ, ព្រមទាំងមាសប្រាក់ដែលវាយកបានពីឃ្លាំងពួកចោរ ដើម្បីទៅនៅឯផ្ទះនោះវិញ ។ ប៉ុន្តែ ការដឹកជញ្ជូន ធ្វើតែនៅវេលាយប់ទេ ។ ជាកិច្ចមួយប្រាប់ឱ្យដឹងនូវការរៀបអាពាហ៍ពិពាហ៍ជាថ្មីម្ដងទៀតជាមួយនឹងបងថ្លៃវា ។ ដោយការរៀបអាពាហ៍ពិពាហ៍ដូច្នេះ គ្មានទាស់ខុសអ្វីនឹងសាសនារបស់យើង, ជនណាម្នាក់ក៏គ្មានការភ្ញាក់ផ្អើលឡើយ ។

ចំណែកឯហាងរបស់កាស៊ីម វាបានប្រគល់ឱ្យទៅកូនប្រុសវា ដោយសន្យាថា បើសិនជាកូនប្រុសវាចេះថែរក្សាហាងនេះ ដោយគតិបណ្ឌិតរៀងទៅ, មិនយូរប៉ុន្មានវានឹងត្រូវបានរៀបការទៅតាមភាពរបស់ខ្លួន ។ អាលី-បាបា គាត់មានកូនប្រុសមួយ ដែលអស់ពេលជា

យូរក្រៃលបន្តិចមកហើយ វាបានរៀនចប់នូវមុខរបរប្រកបការងារ នៅក្នុងផ្ទះមហាពាណិជមួយ ហើយមហាពាណិជននោះតែងពោល សរសើរពីចរិយាសម្បត្តិរបស់យុវជននេះណាស់ ។

យើងសូមទុកឱ្យអាលី-បាបា ឱ្យនៅសប្បាយជាមួយនឹងទ្រព្យ សម្បត្តិ ដែលកើតមានដល់វាដើមដំបូងនេះទៅចុះ, ហើយសូមដំណាល ពីពួកចោរ៤០ នាក់ម្តងវិញ ។ វាបានត្រឡប់មកទីជម្រកវាវិញតាម ពេល ដែលវាបានកំណត់ទុក, ប៉ុន្តែវាមានសេចក្តីងឿងឆ្ងល់ជាក្រៃលែង ដោយពុំបានឃើញខ្លួនកាស៊ីម ។ ការងឿងឆ្ងល់កាន់តែទ្វេឡើង កាល បើវាបានសង្កេតឃើញបាវមាសថយចំនួន, ទើបមេចោរពោលឡើង ថា: “ពួកយើងមានគេស្គាល់កន្លែងហើយៗយើងនឹងត្រូវអន្តរាយទ្រព្យ សម្បត្តិ, បើសិនជាយើងមិនប្រុងប្រយ័ត្ន ឬក៏យើងមិនគិតរកថ្នាំជា ប្រញាប់មកដាក់, បើមិនដូច្នោះទេ យើងនឹងបង់ខាតទ្រព្យសម្បត្តិ បន្តិចម្តងៗ ដែលជីដូនជីតាជីទូតលួតលាយើង ព្រមទាំងយើងបានខំរក យកមកទុកដោយការលំបាកនិងការនឿយហត់ជាទីបំផុត ។ ការដែល យើងអាចវិនិច្ឆ័យបាន ដល់ការខូចខាតទ្រព្យរបស់យើងនោះ គឺចោរ ដែលយើងចាប់បាននេះ វាដឹងការសម្ងាត់សម្លាប់បើកទ្វារ ហើយសំណាង ល្អយើងក៏បានមកទាន់ចំពេលដែលវាត្រូវចេញ ។ ប៉ុន្តែមិនមែនមាន តែម្នាក់ឯងទេ, ប្រាកដជាមាននរណាម្នាក់ទៀត អាចដឹងការសម្ងាត់ នេះដែរ ។ ខ្លួនខ្មោចបាត់ទ្រព្យសម្បត្តិរលោះអស់នេះ ជាសញ្ញាយ៉ាង



ពិតប្រាកដ ។ តែដោយយើងសង្កេតឃើញថា មានតែមនុស្សពីរនាក់ ប៉ុណ្ណោះទេ ដែលដឹងការអាថិកំបាំង ។ ដូច្នេះបន្ទាប់ពីយើងបានសម្លាប់ ម្នាក់ហើយ, យើងត្រូវតែរកសម្លាប់ម្នាក់ទៀតឱ្យបាន ។ តើក្រុមក្លា- ហានរបស់យើងនេះមានយោបល់ដូចខ្ញុំទេឬ?”

សេចក្តីស្នើរបស់មេចោរក៏ត្រូវពួកកូនចោរអនុមតិយល់ព្រម ទាំងអស់គ្នា, ហើយស្រុះគ្នាថាត្រូវឈប់ធ្វើការដទៃទៀតសិន, ដើម្បី មកគិតអំពីតែរឿងមួយនេះ លុះត្រាតែបានសម្រេច ទើបងាកទៅ ប្រកបការងារវិញ ។

មេចោរក៏ពោលថា: “ខ្ញុំសង្ឃឹមយ៉ាងមាំទៅលើសេចក្តីក្លា- ហាននិងមុះមុតរបស់អ្នកទាំងឡាយ ។ ប៉ុន្តែដំបូងបង្អស់ ត្រូវរកនរណា ម្នាក់បណ្តាគ្នាយើងដែលមានចិត្តមុត, ប៉ិនប្រសប់, ឈ្លាសវៃឱ្យទៅ កាន់ទីក្រុងដោយខ្លួនទទេគ្មានអាវុធ, ស្លៀកពាក់ជាអ្នកបម្រើមកពីទី ឆ្ងាយដើម្បីស៊ើបសួរស្តាប់ការ តើមានគេនិយាយអំពីការស្លាប់ដ៏ចម្លែក នៃជន ដែលយើងបានសម្លាប់ទេ ហើយតើជននោះជានរណា ផ្ទះនៅ កន្លែងណា ។ នេះជាការសំខាន់ដែលយើងត្រូវដឹងជាមុន, ដើម្បីកុំឱ្យ ធ្វើការអ្វីទៅមានការស្តាយក្រោយ, ប្រយោជន៍កុំឱ្យគេស្គាល់កន្លែង យើងក្នុងនគរ ដែលយើងមិនទាំងស្គាល់ផងនេះ, ហើយដែលជាកន្លែង បានផ្តល់ប្រយោជន៍ដល់យើងយ៉ាងសម្បើម និងត្រូវផ្តល់ប្រយោជន៍ ដល់យើងតទៅទៀត ។ ប៉ុន្តែ ដើម្បីកុំឱ្យគ្នាយើងណា ដែលស្ម័គ្រចិត្ត

ទៅធ្វើបេសកកម្មនេះមានការធ្វេសប្រហែស, ភ័ន្តច្រឡំ, នាំការណ៍ខុសមិនពិតមកប្រាប់យើង ដែលជាហេតុនាំឱ្យយើងទាំងអស់គ្នាវិនាសអន្តរាយ, ខ្ញុំសូមចិត្តអ្នកទាំងអស់គ្នា បើអ្នកទាំងអស់គ្នាមិនយល់ទាស់ថានឹងធ្វើទោសជននោះដល់ជីវិត បើសិនជាជននោះនាំការមិនពិតមកប្រាប់" ។

ដោយឥតបង្អង់ឱ្យពួកចោរឯទៀតជ្រើសរើសនរណាម្នាក់ទាន់, កូនចោរម្នាក់ក៏ឆ្លើយឡើងថា : "ខ្ញុំទទួលយល់ព្រមឥតរួញរា, ហើយខ្ញុំសូមប្រគល់ជីវិតខ្ញុំចំពោះបេសកកម្មនេះ ។ ហើយបើសិនជាខ្ញុំធ្វើការនេះពុំបានសម្រេចទេ, សូមអ្នកទាំងអស់គ្នានឹកក្នុងចិត្តដូច្នេះថា, ខ្ញុំមិនមែនទាន់អស់មធ្យោបាយនិងសេចក្ដីក្លាហាន ដើម្បីធ្វើការជាផលប្រយោជន៍រួមដល់ពួកក្រុមយើងឡើយ"។

កូនចោរនោះ, ក្រោយពីបានទទួលសេចក្ដីសរសើរពីមេចោរនិងពួកភឿនខ្លួនរួច, ក៏ស្លៀកពាក់ក្លែងក្លាយជារបៀប ដែលគ្មាននរណាម្នាក់អាចសម្គាល់បានថា ខ្លួនជាអ្វីនោះឡើយ ។ នៅវេលាយប់, កូនចោរនោះក៏បែកចេញពីក្រុមខ្លួនទៅ, សំដៅចូលទៅទីក្រុង ឱ្យត្រូវនឹងពេលដែលព្រះអាទិត្យទើបនឹងចាប់រះឡើង ។ ជនក្លែងខ្លួនបានចូលទៅដល់កន្លែងមួយ ដែលឃើញមានតែហាងមួយគត់បើកទ្វារ គឺជាហាងរបស់បាបា-មុស្ដាហ្វា ។

បាបា-មុស្ដាហ្វា កំពុងអង្គុយនៅលើកន្លែងមួយ ដៃកាន់ដែក



ចោះ ប្រុងនឹងចាប់ធ្វើការ ។ ចោរក៏ចូលទៅជិតគាត់ ដោយលើកដៃសំពះ ។ ហើយដោយចោរនោះឃើញគាត់មានវ័យច្រើន វាក៏និយាយថា "លោកអ៊ំ, លោកអ៊ំភ្ញាក់ធ្វើការតាំងពីព្រលឹមធំ អាយុចំណាស់នេះហើយ លោកអ៊ំនៅតែមើលឃើញទៀត ចុះទម្រាំតែថ្ងៃរះពេញពន្លឺ, នោះលោកអ៊ំរឹតតែមើលឃើញច្បាស់ទៅទៀត ដើម្បីនឹងដេររបស់ផ្សេងៗ ។

អ្នកឯងជានរណា, (បាបា-មុស្ដាហ្វាពោល) បានជាឯងពុំស្គាល់ខ្ញុំ ចាស់តែខ្លួនមែន, ប៉ុន្តែភ្នែកខ្ញុំនៅភ្លឺល្អណាស់ ។ ការនេះអ្នកឥតសង្ស័យឡើយ បើសិនជាអ្នកនឹងបានដឹងថា ទើបតែពីប៉ុន្មានថ្ងៃមុននេះខ្ញុំបានដេរខ្លួនខ្មោចមួយ នៅក្នុងកន្លែងដ៏ងងឹតជាងនេះទៅទៀត ។

ទុរជនក៏មានសេចក្ដីរីករាយជាក្រៃលែង, ដោយបានសួរជាដំបូងបង្អស់ ចំពោះជនដែលបានឱ្យការត្រូវតាមចំណុចចិត្តខ្លួន, ដោយវាមិនទាន់ទាំងសួរផង ។

មនុស្សស្លាប់ !, ចោរសួរដោយងឿងឆ្ងល់ហើយ ដើម្បីនឹងធ្វើឱ្យជាងដេរស្បែកជើងនិយាយតទៅទៀត, វាក៏បន្ថែមថា : "ហេតុអ្វីបានជាដេរមនុស្សស្លាប់? អម្បាញ់មិញ, លោកអ៊ំចង់មានប្រសាសន៍ថាលោកអ៊ំបានដេរកំណាត់ស្បូ ដែលរុំបុគ្គលឬ? ទេ, ទេ, មិនមែនទេ, មុស្ដាហ្វាឆ្លើយ, អ៊ំយល់ច្បាស់ណាស់នូវការដែលអ៊ំចង់និយាយនោះ ។ អ្នកឯងចង់សួរឱ្យអ៊ំនិយាយតទៅទៀត, ប៉ុន្តែឥតប្រយោជន៍ឡើយ អ្នកឯងពុំអាចដឹងតទៅទៀតទេ" ។

ជនហានេយ្យំ ក៏ឈប់សួរតាជាងឱ្យល្អិតល្អន់ជាងនេះតទៅទៀត ប្រយោជន៏កុំឱ្យគេដឹងថា វាមកនេះដើម្បីអ្វី ។ វាបែរជាទាញយកលុយមាសមួយដុំ ដាក់ទៅក្នុងដៃមុស្តាហ្វា ហើយបន្តសកម្មភាពថាៈ "ខ្ញុំឥតមានបំណងនឹងសួរចាក់ឬស ចាក់គល់ការអាថ៌កំបាំងរបស់លោកអ៊ំទេ, ពិតមែនតែខ្ញុំអាចធានាជូនលោកអ៊ំថា ខ្ញុំនឹងមិននិយាយការសម្ងាត់នេះឱ្យសាធារណជនដឹងឡើយ បើសិនជាលោកអ៊ំបានប្រាប់ខ្ញុំ ។ ការតែមួយដែលខ្ញុំត្រូវសូមអង្វរលោកអ៊ំ, គឺសូមឱ្យលោកអ៊ំមេត្តាប្រាប់ ឬក៏អញ្ជើញទៅចង្អុលបង្ហាញផ្ទះណា ដែលលោកអ៊ំបានដេរខ្លួនសពនោះតែប៉ុណ្ណោះ ។

ទេ ! ឱ្យខ្ញុំយល់ព្រមតាមពាក្យអ្នកសុំនេះ, នោះខ្ញុំសូមបញ្ជាក់ថា ខ្ញុំពុំអាចធ្វើបានសោះឡើយ, សូមលោកជឿតាមសម្ដីខ្ញុំនេះចុះ ។ មុស្តាហ្វានិយាយបណ្ដើរ ដៃលូកកាន់លុយបណ្ដើរ ប្រុងតែនឹងហុចទៅឱ្យចោរវិញ ។ តទៅនេះជាហេតុនាំឱ្យខ្ញុំប្រកែក : គឺគេបាននាំខ្ញុំទៅកន្លែងមួយ, រួចគេក៏យកកន្សែងមករុំមុខខ្ញុំ, ហើយចាប់តាំងពីកន្លែងនោះទៅ ខ្ញុំបណ្ដោយឱ្យគេដឹកនាំតាមចិត្ត លុះត្រាតែទៅដល់ផ្ទះមួយ រួចកាលបើខ្ញុំបំពេញកិច្ចឱ្យគេហើយ គេក៏នាំខ្ញុំរហូតមកដល់កន្លែងដដែលវិញ ។ អ្នកឃើញទេ នេះហើយជាអលទ្ធភាពដែលខ្ញុំពុំអាចបំពេញចិត្តអ្នកបាន ។

យ៉ាងហោចណាស់, ក៏សូមឱ្យលោកអ៊ំនឹកប្រហែលៗដល់ផ្លូវ



ដែលគេបានរុំភ្នែកលោកអ៊ុំ, កូនចោរអង្វរ, ។ ដូច្នេះ ខ្ញុំសូមចិត្តលោកអ៊ំ, សូមឱ្យលោកអ៊ំអញ្ជើញមកជាមួយខ្ញុំ ហើយខ្ញុំនឹងរុំភ្នែកលោកអ៊ំនៅត្រង់កន្លែងដែលគេបានរុំភ្នែកលោកអ៊ំនោះ ហើយយើងនឹងដើរទៅទាំងអស់គ្នាតាមផ្លូវដដែល និងតាមទីបត់បែនដែលលោកអ៊ំអាចចាំបានខ្លះនៅក្នុងខួរក្បាល ។ ហើយដោយការលំបាកទាំងអស់សុទ្ធតែត្រូវបានរង្វាន់, ខ្ញុំនឹងជូនលុយមាសលោកអ៊ំមួយទៀត ។ អញ្ជើញមកហើយសូមលោកអ៊ំធ្វើឱ្យខ្ញុំសប្បាយចិត្តតាមសេចក្ដីដែលខ្ញុំសុំនេះផង ។ ពោលដូច្នេះរួច ជនប្រវ័ញ្ចក៏ដាក់រូបិយមាសមួយទៀតទៅក្នុងដៃគាត់ ។

រូបិយមាសពីរនេះ បានធ្វើឱ្យលោកតាមុស្តាហ្វាសប្បាយចិត្តជាខ្លាំង ។ គាត់បានប្រឹងសម្លឹងមើលលុយនោះ ឥតប៉ប្រិចភ្នែកអស់រយៈពេលជាយូរ ដោយពិគ្រោះក្នុងចិត្តនូវកិច្ចដែលគាត់ត្រូវធ្វើ, រួចក៏ទាញថង់ប្រាក់ពីក្នុងអាវហើយដាក់លុយនោះចូលទៅ ។ បន្ទាប់មក គាត់ក៏និយាយទៅកាន់កូនចោរថាៈ "ខ្ញុំសូមជម្រាបអ្នកថា ខ្ញុំនឹកឃើញពុំច្បាស់អំពីផ្លូវ ដែលគេបាននាំខ្ញុំទៅនោះទេ ប៉ុន្តែដោយអ្នកពឹងខ្ញុំឱ្យជូនទៅហើយ, ខ្ញុំពុំប្រកែកថាម៉េចទេ, ខ្ញុំនឹងខំធ្វើតាមការដែលខ្ញុំអាចនឹកឃើញ" ។

បាបា-មុស្តាហ្វាក៏ក្រោកឡើង ចោរក៏រីករាយជាពន់ប្រមាណ។ មិនទាំងបិទទ្វារហាងផង ព្រោះគ្មានអ្វីបារម្ភខ្លាចបាត់, គាត់ក៏នាំចោរនោះទៅជាមួយនឹងគាត់ លុះត្រាដល់កន្លែងដែលនាងមរ្ស៊ីយ៉ានបានរុំ